# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "ប.ស.ស"។ ប.ស.ស ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប.ស.ស មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

ប.ស.ស គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

ប.ស.ស ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៣.-**

ប.ស.ស មានភារកិច្ចដូចខាងក្រោម ៖

១- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

២- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃប.ស.ស ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។

៣- ប្រមូលភាគទានពីសមាជិកនៃប.ស.ស និងនិយោជក ។

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី ៖

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និង អនាម័យការងារ ។

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ ។

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

## ជំពូកទី ២

## រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**ប.ស.ស**ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ។

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម ÷

- តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ (មួយ) រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ១( មួយ) រូប សមាជិក
- តំណាងនិយោជក ២(ពីរ) រូប សមាជិក
- តំណាងកម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ២(ពីរ) រូប សមាជិក
- នាយកនៃ **ប.ស.ស** សមាជិកស្វ័យប្រវត្តិ

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃ **ប.ស.ស** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ÷

- អនុម័តថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ជាពិសេសសម្រាប់តាវកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច

- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

**មាត្រា ៦.-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬ នីតិសាស្ត្រ និង មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី) ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះ តំណាងឱ្យ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣(បី)ខែ។ ទោះជាមានកំណត់ដូច្នេះក្ដី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ប.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើរបស់នាយកនៃ**ប.ស.ស** ឬ សមាជិកដែលមានចំនួន ៥ (ប្រាំ) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ប.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុង សម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិក ក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិន បើខ្វះកូរ៉ុមការប្រជុំត្រូវលើកទៅ ១៥(ដប់ប្រាំ)ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជា ការបាន លុះណាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្ដមានុភាព។

**មាត្រា ៨.-**

សេចក្ដីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ប.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០(ដប់)ថ្ងៃយ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសំគាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងអស់នោះ ក្នុងកំណត់ហេតុនៃកាប្រជុំចុងក្រោយនេះផង។

**មាត្រា ៩.-**

លាភការនៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

**មាត្រា ១០.-**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោម ÷

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬ មានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ**ប.ស.ស** ឬ បម្រើសេវាកម្មណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបំពេញភារកិច្ចដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល ។

សមាជិកក្រុមប្រឹក្សាភិបាលរូបណាដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាលដែលបាត់បង់សមាជិកភាពរបស់ខ្លួនត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិនៃ ប.ស.ស

**មាត្រា ១១.-**

នាយកនៃ **ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នាយកនៃ**ប.ស.ស** មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់**ប.ស.ស** ។

មាត្រា ១២.-

នាយកនៃ ប.ស.ស ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃ ប.ស.ស ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃ ប.ស.ស មានភារកិច្ចសំខាន់ៗដូចតទៅ ÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ ប.ស.ស
- ទទួលបន្ទុកដឹកនាំ ប.ស.ស ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ស.ស ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបរបស់ ប.ស.ស ដោយគោរពតាម លក្ខន្តិកៈ ឬ ច្បាប់ជាធរមាន និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬ ផ្តល់លាភការដល់បុគ្គលិករបស់ ប.ស.ស ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការ ស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់មន្ត្រីរាជការ នៃ ប.ស.ស ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ មន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ ប.ស.ស ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ ប.ស.ស និង ទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ ប.ស.ស។

នាយកនៃ ប.ស.ស មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១៣.-**

គណនេយ្យករនៃ **ប.ស.ស** ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពគ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃ **ប.ស.ស** ។

**មាត្រា ១៤.-**

ការត្រួតពិនិត្យនូវការអនុវត្តបទប្បញ្ញត្តិនៃ "ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" នៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើដោយអធិការឬអភិបាលរបបសន្តិសុខសង្គម និងក្នុងករណីចាំបាច់ត្រូវសហការជាមួយអធិការការងារ ឬអភិបាលការងារ និងអង្គភាពពាក់ព័ន្ធដទៃទៀត ។

ការតែងតាំង ការកំណត់តួនាទីភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** ។

**មាត្រា ១៥.-**

បុគ្គលិកអចិន្ត្រៃយ៍របស់**ប.ស.ស**រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬ មន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ **ប.ស.ស** ។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ។

បេឡាជាតិរបបសន្តិសុខសង្គមអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ ។

បុគ្គលិកនៃ **ប.ស.ស**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

**មាត្រា ១៦.-**

រចនាសម្ព័ន្ធគ្រប់គ្រងនៃ**ប.ស.ស**ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** ។

## ជំពូកទី ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

### ផ្នែកទី ១
### កិច្ចការគណនេយ្យ

**មាត្រា ១៧.-**

**ប.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់។

របាយការណ៍ហិរញ្ញវត្ថុត្រូវសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា ១៨.-**

**១៨.១-** នាយកនៃ ប.ស.ស ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលត្រូវមានភារកិច្ច ៖

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរដ្ឋទេយ្យចំណូល ឬបុរេប្រទានបាន ដោយមានការយល់ព្រមពីគណនេយ្យករ។

**១៨.២-** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ប.ស.ស ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នក ពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ។

**១៨.៣-** គណនេយ្យករមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

**១៨.៤-** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យភ្នាក់ងាររបស់ខ្លួន ។

**មាត្រា ១៩.-**

នៅរៀងរាល់ឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ប.ស.សតាមសំណើរបស់នាយកនៃគ្រឹះស្ថាននេះ ។ កម្មវិធី និងគម្រោងទាំងនេះត្រូវបញ្ជូនទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ប្រភពធនធាន

**មាត្រា ២០.-**

ប្រភពធនធាននៃ **ប.ស.ស** មានដូចខាងក្រោម ÷

១- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត **ប.ស.ស** ។

២- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ។

៣- ភាគទានរបស់សមាជិកនៃ **ប.ស.ស** និង និយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ។

៤- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ ។

៥- ផលចំណេញដែលបានមកពីការវិនិយោគ ។

៦- អំណោយ និងអច្ច័យទានផ្សេងៗ ។

៧- ប្រភពធនធានដទៃទៀតដែល **ប.ស.ស** អាចទទួលបានស្របតាមច្បាប់ ។

## ផ្នែកទី ៣
## ការចំណាយ

**មាត្រា ២១.-**

ការចំណាយរបស់ ប.ស.ស រួមមាន ÷

១- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកទីមួយ។

២- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃ ប.ស.ស ។

៣- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច ។

៤- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ ប.ស.ស ។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ។

## ផ្នែកទី ៤
## ប្រាក់ត្រៀមបម្រុង

**មាត្រា ២២.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង ១/២( មួយភាគពីរ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល ២( ពីរ) ឆ្នាំចុងក្រោយ ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ទាប់ពីបានទទួលសំណើ ពីក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ។

អត្រាភាគទានដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យឡើងវិញក្នុងករណីដែលប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកទីមួយៗធ្លាក់ចុះទាបជាងកម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ ប.ស.ស។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគ ត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា ។

## ផ្នែកទី ៥
## មូលនិធិបម្រុង

**មាត្រា ២៣.-**

ត្រូវបង្កើតឱ្យមានមូលនិធិបម្រុងរួមមួយសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្ដិសុខសង្គម ។ មូលនិធិនេះមិនត្រូវតិចជាង២(ពីរ)ដងនៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ **ប.ស.ស** នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។

## ផ្នែកទី ៦
## ការវិភាគសន្ដិសុខសង្គម

**មាត្រា ២៤.-**

**ប.ស.ស** ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្ដិសុខសង្គមយ៉ាងយូរបីឆ្នាំម្ដង ។ ក្នុងករណីដែលការវិភាគនេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ **ប.ស.ស** ត្រូវស្នើសុំធ្វើការកែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើរការរបស់ **ប.ស.ស** ។

រដ្ឋត្រូវផ្ដល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ស.ស** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា ។

# ជំពូកទី ៤
# ភាគទាន និងតារាងកាលិកសន្ដិសុខសង្គម

## ផ្នែកទី ១
## ភាគទាន

**មាត្រា ២៥.-**

អត្រានៃភាគទានសម្រាប់ផ្នែកនីមួយៗនៃរបបសន្ដិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ ស្ដីពីរបបសន្ដិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ២

## តាវកាលិក

**មាត្រា ២៦.-**

អត្រានៃតាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

ទម្រង់នៃការស្នើសុំតាវកាលិកទាំងអស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

## ជំពូកទី ៥

## អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៧.-**

**២៧.១-** ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយកនៃ**ប.ស.ស**ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយនាយកនៃ **ប.ស.ស** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២** -លិខិតយល់ព្រមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើជូនទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។នាយកនៃ**ប.ស.ស** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ ។

កម្មវិធីអភិវឌ្ឍនៃប.ស.ស និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើងដោយប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា១២(ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។ ទោះជាយ៉ាងនេះក្តី ថវិកាចំណាយសម្រាប់តាវកាលិកដែលត្រូវផ្តល់ឱ្យកម្មករនិយោជិតត្រូវដាក់ឱ្យអនុវត្តបាន ។

**មាត្រា ២៨.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនរួមមាន កម្មវិធីអភិវឌ្ឍ គម្រោងថវិកាប្រចាំឆ្នាំ និងកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានរយៈពេល១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងនោះ ។

នាយកនៃប.ស.សត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសម្រេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ២៩.-**

**២៩.១**- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ ប.ស.ស ក្នុងករណីដែលសេចក្តីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់ **ប.ស.ស**
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ៧ ។

**២៩.២**- ការលុបចោល ឬការផ្អាកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុប

ចោល ឬការផ្អាកសេចក្តីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ប.ស.ស**។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះបន្តទៅក្រុមប្រឹក្សាភិបាល **ប.ស.ស** ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុង **ប.ស.ស** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ៣១.-**

**៣១.១-** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ប.ស.ស** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល១(មួយ) ខែ គិតចាប់ពីថ្ងៃដែលទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលទទួលបានឯកសារដែលបញ្ជូនមកដោយនាយកនៃ**ប.ស.ស**ដើម្បីសម្រេចផ្តល់ ការយល់ព្រមលើឯកសារនេះ។

**៣១.២-** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវបានសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយនោះ។

**មាត្រា ៣២.-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ**ម.ស.ស**ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬ លិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣៣.-**

ត្រូវដាក់ឱ្យនៅអមម**ម.ស.ស**នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនេះ មានភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើ **ម.ស.ស** ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ម.ស.ស** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៣៤.-**

**៣៤.១-** សិទ្ធិវិន្ថ្លរបស់សមាជិកនៃ **ម.ស.ស** ដែលត្រូវទទួលបាន "តាវកាលិកឧត្តរជីវី" ត្រូវកំណត់ដូចខាងក្រោម ÷

ក-ប្តី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្តីឬប្រពន្ធ ដែលជាសមាជិកនៃ **ប.ស.ស**។

ខ-កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី) ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាព ដូចខាងក្រោម ÷

- កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬ ករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិ ដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ
- កូនចិញ្ចឹមរបស់សមាជិកនៃ **ប.ស.ស**។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១ (ម្ភៃមួយ) ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ ឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និង មានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬ មានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល។

គ- ឪពុកម្តាយ ឬ មនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃ**ប.ស.ស**។

**៣៤.២**- សិទ្ធិវន្តរបស់សមាជិកនៃ**ប.ស.ស**ដែលត្រូវទទួលបាន "តាវកាលិកចំពោះអ្នកនៅក្នុងបន្ទុក" ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការរៀបចំតាវកាលិកផ្នែកប្រាក់សោធន។

**៣៤.៣**- សិទ្ធិធនលាភចំពោះឧត្តរជីវី និងសោធនចំពោះអ្នកនៅក្នុងបន្ទុករបស់សហព័ទ្ធត្រូវផុតរលត់ ក្នុងករណីដែលសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី។

**មាត្រា ៣៥.**-

**ប.ស.ស** មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលចំណូល ការឱ្យសងបំណុល និងការការពារទ្រព្យសម្បត្តិ ។ បុព្វសិទ្ធិនេះអាចអនុវត្តនៅពេល ដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬ ត្រូវបានជម្រះបញ្ជីដោយតុលាការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមរបស់តុលាការ។ នីតិវិធីនៃការទារបំណុលរបស់ **ប.ស.ស** ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ភ្នាក់ងារមានសមត្ថកិច្ចតាមច្រក ត្រូវហាមឃាត់មិនឱ្យចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនណា ដែលមិនទាន់បានសងបំណុល**ប.ស.ស**តាមដីការបស់តុលាការ។

**មាត្រា ៣៦.-**

មូលនិធិរបស់**ប.ស.ស** ត្រូវដាក់ចូលក្នុងគណនី នៅរតនាគារជាតិ ឬនៅធនាគារជាតិនៃកម្ពុជា ឬ នៅធនាគារពាណិជ្ជកម្មផ្សេងៗ ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** អាចសម្រេចឱ្យប្រើប្រាស់នូវប្រាក់ដែលលើស( ប្រាក់ដែលសល់ពីប្រាក់ត្រៀមបម្រុង) សម្រាប់ការវិនិយោគ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៧.-**

រដ្ឋធានាចំពោះតែបំណុលរបស់**ប.ស.ស** ណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៨.-**

ដំណាក់កាល វិសាលភាព នីតិវិធី និងកាលបរិច្ឆេទដាក់លាក់សម្រាប់ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩.-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន នាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្ទេរទៅជាបេឡាជាតិរបបសន្តិសុខសង្គម។ ប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលតួនាទីជានាយកនៃបេឡាជាតិរបបសន្តិសុខសង្គម រហូតមានការតែងតាំងនាយក**ប.ស.ស** ថ្មី។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤១
- ឯកសារ-កាលប្បវត្តិ